ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

-សំណុំរឿងព្រហ្មទណ្ឌ លេខៈ ១០៥៩ អក
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២
-សាលក្រមលេខៈ ៧២ (ឃ)
ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១០៥៩ អក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted]បាវ ភេទប្រុស អាយុ ៣០ឆ្នាំ (កើតឆ្នាំ១៩៩២) ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្នស្នាក់នៅ[redacted]ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted] ឌីល (ស) ម្ដាយឈ្មោះ [redacted] ឡៃហ៊ីម (រ) ប្រពន្ធឈ្មោះ [redacted] វីម មានកូន ០៣នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] និត ភេទប្រុស អាយុ ៣០ឆ្នាំ (កើតឆ្នាំ១៩៩២) ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted]ខេត្តតាកែវ ឪពុកឈ្មោះ[redacted] វ៉ៃ (រ) ម្ដាយឈ្មោះ[redacted]ហៀក (រ) ប្រពន្ធឈ្មោះ[redacted]សម្ផស្ស មានកូន ០៤នាក់ ទោសពីមុនគ្មាន។ (គេចខ្លួន)

៣-ឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅកំណើតនៅភូមិ [redacted]ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល ឪពុកឈ្មោះ មិនស្គាល់ (រ/ស) ម្ដាយឈ្មោះ មិនស្គាល់ (រ/ស) ប្រពន្ធឈ្មោះ[redacted]ស្រីនិត មានកូន ០២នាក់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] បាវ។



Scanned with CamScanner

ជាប់ចោទពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិចុងខ្សាច់ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិធំ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៧ និង ០០នាទីរសៀល ជនរងគ្រោះឈ្មោះ [redacted] ចិន្តា និងអ្នកផ្សេងជាច្រើននាក់ទៀតបានទៅចូលរួមក្នុងកម្មវិធីឡើងផ្ទះរបស់ឈ្មោះ [redacted] រ៉ាត ស្ថិតនៅចំណុចភូមិក្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល។ លុះដល់វេលាម៉ោង ២១ និង ៣០នាទីយប់ ជនរងគ្រោះឈ្មោះ [redacted] ចិន្តា ក៏បានរករឿងទាស់សំដីជាមួយនឹងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់ប្រើហិង្សាដាក់គ្នាទៅវិញ ទៅមកឃើញដូច្នេះជនសង្ស័យឈ្មោះ [redacted] បាវ បានកាន់កាំបិតឈ្មោះ [redacted] និត កាន់កៅអីជ័រ និងគប់កៅអីជ័រ ព្រួតវាយមកលើជនរងគ្រោះឈ្មោះ [redacted] ចិន្តា បណ្តាលឱ្យរងរបួសត្រូវចំក្បាល ថ្ពាមុខ និងត្រូវកំភួនដៃខាងស្តាំ មុតរងរបួសចេញឈាមស្រោចពេញខ្លួន។ បន្ទាប់មកនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២ សមត្ថកិច្ចបានធ្វើការ ស្រាវជ្រាវរហូតឈានដល់ធ្វើការឃាត់ខ្លួនឈ្មោះ [redacted] បាវ ព្រមទាំងធ្វើតេស្តិ៍ទឹកនោម ស្វែងរកសារធាតុញៀនជា លទ្ធផល អវិជ្ជមាន។ រីឯឈ្មោះ [redacted] និត និងឈ្មោះ [redacted] ឈី ព្រមទាំងបក្សពួកផ្សេងទៀតបានរត់គេចខ្លួន។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៩៦ ដកសព ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ [redacted] បាវ ភេទប្រុស អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] និត ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ទៅជំនុំជម្រះ។

**បានឃើញ** ដីកាដំណោះស្រាយលេខ ៤២៤ ដកដស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] បាវ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] និត ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ទៅជំនុំជម្រះ ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិក្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

## នាពេលសវនាការ

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បាវ បានធ្វើកត់សំគាល់ថា តាមចម្លើយកូនក្តីខ្ញុំ គាត់បានឆ្លើយថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយជនរងគ្រោះឈ្មោះ [redacted] ចិន្តា បានទាស់សំដីជាមួយនឹងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់ការប្រតាយប្រតប់គ្នា ហើយកូនក្តីនាងខ្ញុំ និងឈ្មោះ [redacted] និត ព្រមទាំងឈ្មោះ [redacted] ឈី និងអ្នកផ្សេងទៀត បានចូលទៅជួយឃាត់ប៉ុណ្ណោះ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បាវ បានធ្វើការកត់សំគាល់ថា តាមពិនិត្យពាក្យបណ្តឹង ឈ្មោះ [redacted]ន្តា បានប្តឹងនៅអធិការដ្ឋាននគរបាលស្រុកកោះធំ ហើយក្រោយមក តំណាងអយ្យការក៏បានសម្រេចចោទប្រកាន់កូនក្តីរបស់ខ្ញុំ ពីបទ ហិង្សាដោយចេតនាមានស្ថាន



Scanned with CamScanner

ទម្ងន់ទោស ប្រព្រឹត្តនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ការចោទប្រកាន់កូនក្ដីខ្ញុំនេះ គឺពីបទ ហិង្សាទៅលើឈ្មោះ [redacted] ចិន្ដា ប៉ុន្តែបើក្រឡេកមើលចម្លើយរបស់សាក្សីនៅក្នុងដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថា គ្រាន់តែឃើញឈ្មោះ [redacted] ឋាវ កាន់កាំបិត ប៉ុន្តែមិនមាននរណាបញ្ជាក់ថា ឈ្មោះ [redacted] ឋាវ បានយកកាំបិតកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ចិន្ដា នោះទេ។ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ចិន្ដា តាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលចៅក្រមស៊ើបសួរ ឆ្លើយថា ដើមបណ្ដឹងខ្លួនផ្ទាល់ ក៏បានមិនបានដឹងថា នរណាកាប់ទៅលើរូបគាត់ពិតប្រាកដទេ។ សូមបញ្ជាក់ថា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ដើមបណ្ដឹងឈ្មោះ [redacted] ចិន្ដា ក៏បានដកពាក្យបណ្ដឹងរួចហើយ។ នេះបញ្ជាក់ថា ដើមបណ្ដឹង គាត់ចង់បញ្ចប់រឿងត្រឹមហ្នឹង។

-មេធាវី [redacted] បានធ្វើការកត់សំគាល់ថា ខ្ញុំបាទសូមបន្ថែមពាក់ព័ន្ធនឹងអង្គហេតុនេះ លើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៥៩អក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល នេះ។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង៣០នាទីយប់ មានអង្គហេតុប្រើហិង្សា មានការទាស់ទែងគ្នា រហូតដល់មានអង្គហេតុមានរបួសស្នាមទៅលើឈ្មោះ [redacted] ចិន្ដា។ នៅក្នុងនោះដែរ គេបានចោទប្រកាន់កូនក្ដីខ្ញុំឈ្មោះ [redacted] ឋាវ ថាបានប្រើហិង្សាទៅលើឈ្មោះ [redacted] ចិន្ដា។ ក៏ប៉ុន្តែបើយើងពិនិត្យមើលទៅលើទំនាក់ទំនងអង្គហេតុនេះ ឈ្មោះ [redacted] ឋាវ និងឈ្មោះ [redacted] ចិន្ដា មិនមានវិវាទគ្នាតាំងពីដំបូងមក។ នៅក្នុងសកម្មភាពហូបចុកមួយ មិនមានទំនាក់ទំនងរវាង [redacted] ឋាវ និងជនរងគ្រោះ ដែលដាក់ពាក្យចោទប្រកាន់ទេ ប៉ុន្តែមានអង្គហេតុហិង្សាមួយបានកើតឡើង មានរបួសស្នាមលើ [redacted] ចិន្ដា ទើបមានការដាក់ពាក្យបណ្ដឹង រហូតដល់មានការស្រាវជ្រាវដល់ដំណាក់កាលចៅក្រមស៊ើបសួរ មិនឃើញមានភស្តុតាងបញ្ជាក់ណាមួយ ថាកូនក្ដីខ្ញុំបាទ ឈ្មោះ [redacted] ឋាវ នេះ បានប្រើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] ចិន្ដា នោះទេ។ នេះជាការកត់សំគាល់របស់ខ្ញុំបាទ ហើយក្រោយពីបានធ្វើការសំភាសន៍កូនក្ដីខ្ញុំមក ឈ្មោះ [redacted] ឋាវ បានបដិសេធថា មិនមានការប្រើហិង្សាដូចការចោទប្រកាន់នោះទេ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឋាវ នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៧ ល្ងាច ពិតជាមានជនរងគ្រោះឈ្មោះ [redacted] ចិន្ដា និងអ្នកផ្សេងទៀតជាច្រើននាក់ បានមកចូលរួមក្នុងកម្មវិធីឡើងផ្ទះរបស់ឈ្មោះ [redacted] វ៉ាត ស្ថិតនៅចំណុចភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល ហើយអំឡុងពេលកម្មវិធីនោះ ជនរងគ្រោះឈ្មោះ [redacted] ចិន្ដា បានទាស់សំដីជាមួយនិងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់មានប្រតាយប្រតប់គ្នា រវាងជនរងគ្រោះឈ្មោះ [redacted] ចិន្ដា និងឈ្មោះ [redacted] ម៉ៅ។ ឃើញដូច្នេះខ្លួនរួមជាមួយនិងឈ្មោះ [redacted] និត ព្រមទាំងឈ្មោះ [redacted] ឈី ព្រមទាំងអ្នកផ្សេងទៀតបានចូលទៅជួយ ដោយខ្លះបានកាន់កៅអីជ័រ ខ្លះប្រើកែវ ប្រើហិង្សាគប់ និងវាយក៏បណ្ដាលឱ្យជនរងគ្រោះឈ្មោះ [redacted] ចិន្ដា រងរបួស ត្រូវចំក្បាល ត្រូវចំផ្ទៃមុខ ជាច្រើនកន្លែង ត្រូវចំកំភួនដៃ ខាងស្ដាំបណ្ដាលឱ្យរបួសចេញឈាម ប្រាកដមែន។ នៅពេលកើតហេតុខ្លួនបានកាន់កាំបិតឈ្មោះ [redacted] ឈី ប្រើដៃ និងឈ្មោះ [redacted] និត កាន់កៅអីជ័ររួមជាមួយអ្នកផ្សេងជាច្រើនទៀត បានប្រើហិង្សាគប់ និងវាយមកលើឈ្មោះ [redacted] ចិន្ដា បណ្ដាលឱ្យរងរបួស ដោយមូលហេតុមកពីក្រុមជនរងគ្រោះឈ្មោះ [redacted] ចិន្ដា បានប្រើហិង្សាវាយមកលើឈ្មោះ [redacted] ម៉ៅ វិញ ទើបឈានដល់មានករណីហិង្សានេះកើតឡើងតែម្ដងទៅ។ ខ្លួនកាន់កាបិតមែន ប៉ុន្តែពុំបានកាប់ទៅលើឈ្មោះ [redacted] ចិន្ដា អ្វីនោះឡើយ។ រីឯឈ្មោះ [redacted] ឈី និងឈ្មោះ [redacted] និត បានប្រើហិង្សា យ៉ាង ម៉េចខ្លះ ខ្លួនពុំដឹងច្បាស់នោះទេ។ មូលហេតុបានជារឿងហេតុកើតឡើង គឺបណ្ដាលមកពីជនរងគ្រោះឈ្មោះ [redacted]



Scanned with CamScanner

ចិន្តា បានមករករឿងឈ្លោះជាមួយនិងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់ប្រើហិង្សាទៅវិញទៅមក ឃើញដូច្នេះ ខ្លួនរួមជាមួយនិងឈ្មោះ [redacted]ឃី និងឈ្មោះ [redacted] និត ព្រមជាមួយអ្នកផ្សេងទៀត បានទៅជួយ រហូតឈានដល់មានការប្រើហិង្សា បណ្តាលឱ្យជនរងគ្រោះឈ្មោះ [redacted] ចិន្តា រងរបួសតែម្តងទៅ។ ខ្លួនពុំធ្លាប់មានទំនាស់ ឬមានគំនុំអ្វីជាមួយគ្នាពីមុននោះទេ។ នៅថ្ងៃកើតហេតុខ្លួនពុំបានវាយទៅលើជនរងគ្រោះទេ ហើយខ្លួនពុំបានដឹងថា អ្នកណាជាអ្នកវាយទៅលើជនរងគ្រោះទេ។ នៅពេលកើតហេតុខ្លួនបានកាន់កាំបិតប៉ុងតោដើរសំដៅទៅកន្លែងគេកំពុងវាយគ្នា ក៏ត្រូវមានអ្នកភូមិចូលមកឃាត់ខ្លួន។ ដើមហេតុដំបូងឈ្លោះគ្នារវាងជនរងគ្រោះនិងឈ្មោះ [redacted] ម៉ៅ បន្ទាប់មកក៏មានការប្រទូសរាយ វាយតប់គ្នាតែម្តង។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះខ្លួនពុំបានវាយទៅលើជនរងគ្រោះឡើយ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ខ្លួនទៅកម្មវិធីឡើងផ្ទះបងជីដូនមួយ នៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ជាមួយប្អូនជីដូនមួយ ពេលទៅដល់ម៉ោង ០៥ល្ងាច ហើយមើលការខុសត្រូវនៅទីនោះរហូតប្រាំបួនយប់ ខ្លួនបានឃើញអ្នកស្គាល់គ្នា ហើយខ្លួនបានចូលទៅសួរថា ហែងឈ្មោះ អាស្មោរមែន ប៉ុន្តែគេថាមិនមែនទេ បន្ទាប់មកខ្លួនសូមស្គាល់គេផង តែគេថាឱ្យស្គាល់មិចមិនដែលស្គាល់ផង ហើយខ្លួនក៏ដើរចេញបានមួយសន្ទុះ ក៏មានគេវាយខ្លួនពីក្រោយចំក្បាល តែខ្លួនមិនដឹងថាជាអ្នកណាឡើយ និងមានអ្នកមកកាប់ត្រូវដៃទៀត តែក៏មិនដឹងថាអ្នកណាជាអ្នកកាប់ដែរ។ ពេលដែលគេវាយខ្លួនត្រូវក្បាល និងកាប់ខ្លួនត្រូវដៃនោះ ខ្លួនមិនដឹងថាអ្នកណាជាអ្នកវាយ និងកាប់ទេ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សំណាង នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ៣០នាទី នៅពេលដែលខ្លួនកំពុងអង្គុយយាមម៉ូតូនៅកម្មវិធីរបស់ឈ្មោះ [redacted] ភឿន ស្ថិតនៅក្នុងភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល នៅពេលនោះខ្លួនបានឃើញឈ្មោះ វណ្ណា ចិន្តា ភេទប្រុស បានរត់ចេញពីរោងកម្មវិធី និងប្រឡាក់ឈាមពេញខ្លួនព្រមទាំងមានការប្រតាយប្រតប់គ្នាដោយខ្លួនពុំបានស្គាល់អ្នកទាំងនោះទេ ឃើញដូច្នេះខ្លួនក៏បានចូលទៅឃាត់ហើយពួកគេក៏បានបែកចេញពីគ្នា បន្ទាប់មកខ្លួនក៏បានឃើញឈ្មោះ បាវ ភេទប្រុស បានកាន់កាំបិតរត់មក ហើយក៏មានប្រជាពលរដ្ឋឃាត់ឈ្មោះ បាវ មិនចូលទៅ បន្ទាប់ឈ្មោះ [redacted] ចិន្តា ក៏បានត្រូវគេយកទៅមន្ទីរពេទ្យទៅ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ពិសិដ្ឋ នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២២ ខ្លួនមានឈ្មោះ [redacted] ចិន្តា ភេទប្រុស , ឈ្មោះ [redacted]រ៉ា ភេទប្រុស , ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស និងប្អូននាក់ទៀតដែលខ្លួនមិនចាំឈ្មោះ បានអង្គុយផឹកស៊ីក្នុងកម្មវិធីឡើងគេហដ្ឋានថ្មី របស់ឈ្មោះ [redacted] ភឿន ភេទស្រី នៅក្នុងភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ពេលកំពុងតែផឹកស៊ីពេលនោះឈ្មោះ [redacted] ចិន្តា បានទាស់ពាក្យសំដីគ្នាជាមួយបុរសម្នាក់ដែលអង្គុយតុជាមួយគ្នា អង្គុយជាប់ខ្លួនកុំអោយទាស់ពាក្យសំដីគ្នា ស្រាប់តែពេលនោះបក្ខពួករបស់បុរសដែលអង្គុយជាប់ខ្លួនប្រមាណ ជាជិតដប់នាក់ មានអ្នកខ្លះកាន់កែវក្នុងដៃ អ្នកខ្លះកាន់កៅអី អ្នកខ្លះកាន់កាំបិត មកព្រួតគ្នាវាយឈ្មោះ [redacted] ចិន្តា ឃើញដូច្នេះខ្លួនក៏ចូលទៅឃាត់ក៏ត្រូវគេវាយត្រូវមួយកៅអីជំក្បាលពីលើ ខ្លួនបានដើរចេញឃើញបុរសម្នាក់ដែលជាអ្នកចាក់ម៉េក្រូបានយកកាំបិតកាប់ទៅលើឈ្មោះ [redacted] ចិន្តា និងបក្ខពួក បានព្រួតគ្នាវាយមកមានគេឃាត់យកឈ្មោះ [redacted] ចិន្តា ចូលក្នុងផ្ទះម្ចាស់កម្មវិធី ទើបគេបែកគ្នាចេញទៅបាត់អស់ទៅ ដោយឃើញឈ្មោះ [redacted] ចិន្តា រងរបួសដៃ និងក្បាលហូរឈាមច្រើនពេក ក៏ត្រូវគេដឹកបញ្ជូនទៅកាន់មន្ទីរពេទ្យទៅ។ បន្តិចក្រោយមកសមត្ថកិច្ចប៉ុស្តិ៍ឈើខ្មៅ ផ្ទះខ្លួនវិញមក។



Scanned with CamScanner

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ពិសិដ្ឋ នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ដោយមានបងប្អូនស្គាលគ្នាបានហៅក្នុងកម្មវិធីឡើងផ្ទះនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល លុះដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង ៣០នាទី លុះបានទៅដល់ក៏បានជួបជុំបងប្អូននាក់ភូមិជាមួយគ្នា ដោយឈ្មោះ [redacted] ចិន្តា ភេទប្រុស នៅភូមិជាមួយគ្នា , ឈ្មោះ [redacted] ប៉ូវ៉ា ភេទប្រុស និងឈ្មោះ [redacted] ពិសិទ្ធ ភេទប្រុស និងខ្លួនផ្ទាល់ក្រៅពីនេះបងប្អូននាក់នៅត្រើយកោះ ពេលនោះភ្ញៀវទៅផ្ទះផិតអស់ហើយ អ្នករាំក៏ផិតទៅផ្ទះអស់ដែរ លុះដល់ម៉ោង ២១ ក៏នាំបងប្អូនប្រមូលគួបគ្នាតុពីរ ជាមួយបងប្អូននាក់ត្រើយកោះ ក៏ជល់កែវគ្នាទៅវិញទៅមករួចក៏បានទាស់ពាក្យសំដីគ្នាជាមួយឈ្មោះ [redacted] ចិន្តា និងអ្នកផ្សេង ស្រាប់តែខ្លួនឃើញមនុស្សម្នាក់ទៀតរត់ទៅយកកាំបិតធ្វើត្រីរត់មកវិញ ចំណែកកាប់នៅលើជនរងគ្រោះ ក៏ខ្លួនពុំបានឃើញបន្ទាប់មកក៏ឃើញចំដែលឈាមក្បាលរត់ចេញមកក្រៅ ហើយពួកខ្លួនក៏យកជនរងគ្រោះទៅមន្ទីពេទ្យទៅ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ម៉ៅ នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៩ និង ០០នាទី ខ្លួនបានទៅចូលមករួមកម្មវិធីឡើងគេហដ្ឋានថ្មី របស់ឈ្មោះ [redacted] ភឿន នៅក្នុងភូមិជាមួយគ្នា ពេលទៅដល់ខ្លួនបានចូលរួមកម្មវិធី ដោយបានអង្គុយតុជាមួយអ្នកនៅក្នុងភូមិជាមួយគ្នា ហើយក្រោយមកតុខ្លួនបានបែកគ្នាខ្លួនក៏ដើរចេញមកផ្ទះវិញ ដើរចេញបានបន្តិចអ្នកភូមិម្នាក់ដែលខ្លួនមិនចាំឈ្មោះ បានហៅខ្លួនអោយចូលតុជាមួខ្លួនក៏ចូលទៅអង្គុយ ដោយក្នុងតុនោះមានអ្នកក្រៅភូមិដែលខ្លួនមានស្គាល់ឈ្មោះ អង្គុយរួមតុដែរ ពីរបីនាក់ ខ្លួនបានអង្គុយក្បែរបុរសម្នាក់ដែលខ្លួនមិនស្គាល់ ពេលខ្លួនកំពុងតែផឹកម្នាក់ដែលអង្គុយជាប់ខ្លួននោះបានសួរខ្លួនថា ឯងអាស្មោមែន ខ្លួនក៏ប្រាប់ថា អាស្មោ ហើយគ្រាន់តែនិយាយមិនទាន់ផុតមាត់ផង ស្រាប់តែម្នាស់ដែលសួរខ្លួននោះបានចាប់ក្បាលខ្លួនអុកទៅលើតុ ខ្លួនស្ទុះរកវាយវិញក៏ត្រូវឈ្មោះ [redacted] គង់ បានចាប់ខ្លួនជាប់ ពេលនោះម្នាក់ដែលចាប់ខ្លួន អុកក្បាលជាមួយតុបានរត់ចេញទៅខាងក្រៅរោង ខ្លួនឃើញគេផ្អើលឈ្លូសខាងក្រៅ រោងកម្មវិធី តែមិនបានដឹងថា អ្នកណាវាយអ្នកណាឡើយ ដោយខ្លួនទៅខាងក្នុងរោង រហូតដល់ស្ងាត់បែកគ្នាអស់ទើបឈ្មោះ [redacted] គង់ លែងខ្លួន ខ្លួនក៏ដើរត្រឡប់មកដេកនៅផ្ទះវិញទៅ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] គង់ នាពេលសវនាការបានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ៣០នាទី ខ្លួនបានចូលរួមកម្មវិធីឡើងផ្ទះរបស់ឈ្មោះ [redacted] ភឿន ស្ថិតនៅក្នុងភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ដោយខ្លួនបានអង្គុយតុជាមួយឈ្មោះ [redacted] ម៉ៅ ភេទប្រុស ឈ្មោះ [redacted] ចិន្តា ភេទប្រុស និងអ្នកមួយចំនួនទៀត ដែលពុំបានស្គាល់ឈ្មោះ បន្ទាប់មកឈ្មោះ [redacted] ចិន្តា ក៏បានសុំឈ្មោះ [redacted] ម៉ៅ ចាប់ដៃ ហើយឈ្មោះ [redacted] ម៉ៅ ក៏បានហុចដៃទៅចាប់ប៉ុន្តែឈ្មោះ [redacted] ចិន្តា ពុំបានចាប់ដៃទ បែរជាចាប់ក្បាលឈ្មោះ [redacted] ម៉ៅ បោកនិងតុ បណ្តាលឱ្យពក បន្ទាប់មកឈ្មោះ [redacted] ចិន្តា ក៏បានរត់ចេញទៅខាងក្រៅ ហើយខ្លួនក៏បានឃាត់ឈ្មោះ [redacted] ម៉ៅ មិនអោយចេញទៅតាម ហើយខ្លួន និងឈ្មោះ [redacted] ម៉ៅ ក៏បានអង្គុយហូបស្រាបៀរបន្តទៀត មួយសន្ទុះក្រោយមកខ្លួន និងឈ្មោះ ម៉ៅ ក៏បានដើរចេញមកក្រៅ ក៏លឺគេនិយាយថា មានគេវាយគ្នា ខ្លួន និងឈ្មោះ [redacted] ម៉ៅ ក៏បានដើរត្រឡប់ទៅផ្ទះរៀងខ្លួន ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ជនជាប់ចោទពិតជាបានប្រើហិង្សាដោយប្រើកាំបិតកាប់មកលើជនរងគ្រោះ បណ្តាលឱ្យរងរបួស ប្រាកដមែន តំណាងអយ្យការយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បាវ ភេទប្រុស អាយុ ៣០ឆ្នាំ , ឈ្មោះ [redacted] និត ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ



Scanned with CamScanner

ត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះតំណាងអយ្យការនៅតែតំកល់ការចោទប្រកាន់ទុកជាបានការដដែល។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា នាងខ្ញុំស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចផុតបទចោទប្រកាន់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា ការចោទប្រកាន់កូនក្តីខ្ញុំពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស គឺមិនមានភស្តុតាងច្បាស់លាស់នោះទេ បើយោងតាមចម្លើយរបស់កូនក្តីខ្ញុំផ្ទាល់ យោងតាមចម្លើយរបស់សាក្សីឈ្មោះ [redacted]សំណាង, ឈ្មោះ [redacted] ម៉ៅ និងឈ្មោះ [redacted]គង់ ក៏បានបង្ហាញថា ពុំបានឃើញកូនក្តីខ្ញុំកាប់ទៅលើជនរងគ្រោះនោះដែរ។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ជនរងគ្រោះផ្ទាល់ ក៏បានសុំដកពាក្យបណ្តឹង ដែលនេះបង្ហាញថា អង្គហេតុនេះពិតជាមិនមាន ហើយជនរងគ្រោះក៏មិនចង់ឱ្យរឿងក្តីនេះធំដែរ។ ដូច្នេះ ខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំ រួចផុតបទចោទប្រកាន់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីធ្វើសវនាការ និងការពិនិត្យសំណុំរឿងយ៉ាងយកចិត្តទុកដាក់ ឃើញថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង៣០នាទីយប់ មានទំនាស់កើតឡើងរវាងឈ្មោះ [redacted] ចិន្តា ជាមួយភាគីផ្សេងទៀត ដែលមិនមែនកូនក្តីខ្ញុំបាទឈ្មោះ [redacted]បាវ នោះទេ។ ពាក់ព័ន្ធនឹងរបួស [redacted] ចិន្តា មិនឃើញថា នរណាច្បាស់លាស់ដែលធ្វើឱ្យគាត់មានរបួសទេ។ ក្រោយមានរឿងកើតឡើង ក្រោយមានការសម្របសម្រួលគ្នា ជនរងគ្រោះក៏បានធ្វើការដកពាក្យបណ្តឹង ដោយឈប់ទាមទារសំណងពីកូនក្តីខ្ញុំ។ នេះបញ្ជាក់ឃើញថា ជនរងគ្រោះ គាត់មិនមានភាពច្បាស់លាស់ថា នរណាធ្វើឱ្យគាត់របួសទេ ហើយការកើតឡើងនោះ គឺស្ថិតនៅក្នុងហ្វូងមនុស្សច្រើន។ តាមចម្លើយរបស់ជនរងគ្រោះ គាត់ក៏មិនដឹងថា នរណាជាអ្នកធ្វើឱ្យគាត់របួសទេ។ ហើយរបួសគាត់ទៀតសោត ក៏មិនបានបញ្ជាក់ថា របួសនោះ កើតដោយសារអ្វីដែរ តាមមាត្រា ៣៨ វិមតិសង្ស័យ គឺជាប្រយោជន៍របស់ជនជាប់ចោទ។ ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្ញុំ ពិតជាមិនបានប្រព្រឹត្តដូចការចោទប្រកាន់តាមមាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌទេ។ ហេតុដូច្នេះ ខ្ញុំស្នើសុំឱ្យលោកស្រីចៅក្រមសម្រេចឱ្យកូនក្តីខ្ញុំរួចផុតបទចោទប្រកាន់ឱ្យក្តីអនុគ្រោះ។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកណ្តាល**

**យល់ឃើញថា**

-តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរលេខៈ ៤២៤ ដកដស ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ ២០២៣ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]បាវ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted]និត ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិ



Scanned with CamScanner

ខ្មែរ ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាវ បានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៧ ល្ងាច ពិតជាមានជនរងគ្រោះឈ្មោះ [redacted] ចិន្ដា និងអ្នកផ្សេងទៀតជាច្រើននាក់ បានមកចូលរួមក្នុងកម្មវិធីឡើងផ្ទះរបស់ឈ្មោះ [redacted] រ៉ាត ស្ថិតនៅចំណុចភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល ហើយអំឡុងពេលកម្មវិធីនោះ ជនរងគ្រោះឈ្មោះ [redacted] ចិន្ដា បានទាស់សំដីជាមួយនិងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់មានប្រតាយប្រតប់គ្នា រវាងជនរងគ្រោះឈ្មោះ [redacted] ចិន្ដា និងឈ្មោះ [redacted] ម៉ៅ។ ឃើញដូច្នេះខ្លួនរួមជាមួយនិងឈ្មោះ [redacted] និត ព្រមទាំងឈ្មោះ [redacted] ឈី ព្រមទាំងអ្នកផ្សេងទៀតបានចូលទៅជួយដោយខ្លះបានកាន់កៅអីជ័រ ខ្លះប្រើកែវ ប្រើហិង្សាគប់ និងវាយក៏បណ្ដាលឱ្យជនរងគ្រោះឈ្មោះ [redacted] ចិន្ដា រងរបួស ត្រូវចំក្បាល ត្រូវចំផ្ទៃមុខ ជាច្រើនកន្លែង ត្រូវចំកំភួនដៃ ខាងស្ដាំបណ្ដាលឱ្យរបួសចេញឈាម ប្រាកដមែន។ នៅពេលកើតហេតុខ្លួនបានកាន់កាំបិតឈ្មោះ [redacted] ឈី ប្រើដៃ និងឈ្មោះ [redacted] និត កាន់កៅអីជ័ររួមជាមួយអ្នកផ្សេងជាច្រើនទៀត បានប្រើហិង្សាគប់ និងវាយមកលើឈ្មោះ [redacted] ចិន្ដា បណ្ដាលឱ្យរងរបួស ដោយមូលហេតុមកពីក្រុមជនរងគ្រោះឈ្មោះ [redacted] ចិន្ដា បានប្រើហិង្សាវាយមកលើឈ្មោះ [redacted] ម៉ៅ វិញ ទើបឈានដល់មានករណីហិង្សានេះកើតឡើងតែម្ដងទៅ។ ខ្លួនកាន់កាបិតមែន ប៉ុន្ដែពុំបានកាប់ទៅលើឈ្មោះ [redacted] ចិន្ដា អ្វីនោះឡើយ។ រីឯឈ្មោះ [redacted] ឈី និងឈ្មោះ [redacted] និត បានប្រើហិង្សា យ៉ាង ម៉េចខ្លះ ខ្លួនពុំដឹងច្បាស់នោះទេ។ មូលហេតុបានជារឿងហេតុកើតឡើង គឺបណ្ដាលមកពីជនរងគ្រោះឈ្មោះ [redacted] ចិន្ដា បានមករករឿងឈ្លោះជាមួយនិងឈ្មោះ [redacted] ម៉ៅ រហូតឈានដល់ប្រើហិង្សាទៅវិញទៅមក ឃើញដូច្នេះ ខ្លួនរួមជាមួយនិងឈ្មោះ [redacted] ឈី និងឈ្មោះ [redacted] និត ព្រមជាមួយអ្នកផ្សេងទៀត បានទៅជួយ រហូតឈានដល់មានការប្រើហិង្សា បណ្ដាលឱ្យជនរងគ្រោះឈ្មោះ [redacted] ចិន្ដា រងរបួសតែម្ដងទៅ។ ខ្លួនពុំធ្លាប់មានទំនាស់ ឬមានគំនុំអ្វីជាមួយគ្នាពីមុននោះទេ។ នៅថ្ងៃកើតហេតុខ្លួនពុំបានវាយទៅលើជនរងគ្រោះទេ ហើយខ្លួនពុំបានដឹងថា អ្នកណាជាអ្នកវាយទៅលើជនរងគ្រោះទេ។ នៅពេលកើតហេតុខ្លួនបានកាន់កាំបិតប៉ុងតោដើរសំដៅទៅកន្លែងគេកំពុងវាយគ្នា ក៏ត្រូវមានអ្នកភូមិចូលមកឃាត់ខ្លួន។ ដំបូងឈ្មោះគ្នារវាងជនរងគ្រោះនិងឈ្មោះ [redacted] ម៉ៅ បន្ទាប់មកក៏មានការប្រទូសសារាយ វាយគប់គ្នាតែម្ដង។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះខ្លួនពុំបានវាយទៅលើជនរងគ្រោះឡើយ។

-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្ដា បានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២២ ខ្លួនទៅកម្មវិធីឡើងផ្ទះបងជីដូនមួយ នៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល ជាមួយប្អូនជីដូនមួយ ពេលទៅដល់ម៉ោង ០៥ល្ងាច ហើយមើលការខុសត្រូវនៅទីនោះរហូត ប្រាំបួនយប់ ខ្លួនបានឃើញអ្នកស្គាល់គ្នា ហើយខ្លួនបានចូលទៅសួរថា ហែងឈ្មោះ អាស្មោរមែន ប៉ុន្ដែគេថាមិនមែនទេ បន្ទាប់មកខ្លួនសូមស្គាល់គេផង តែគេថាឱ្យស្គាល់មិចមិនដែលស្គាល់ផង ហើយខ្លួនក៏ដើរចេញបានមួយសន្ទុះក៏មានគេវាយខ្លួនពីក្រោយចំក្បាល តែខ្លួនមិនដឹងថាជាអ្នកណាឡើយ និងមានអ្នកមកកាប់ត្រូវដៃទៀត តែក៏មិនដឹងថាអ្នកណាជាអ្នកកាប់ដែរ។ ពេលដែលគេវាយខ្លួនត្រូវក្បាល និងកាប់ខ្លួនត្រូវដៃនោះ ខ្លួនមិនដឹងថាអ្នកណាជាអ្នកវាយ និងកាប់ទេ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សំណាង បានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ៣០នាទី នៅពេលដែលខ្លួនកំពុងអង្គុយយាមម៉ូតូនៅកម្មវិធីរបស់ឈ្មោះ [redacted] ភឿន ស្ថិតនៅក្នុង



Scanned with CamScanner

ភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល នៅពេលនោះខ្លួនបានឃើញឈ្មោះ [redacted] ចិន្តា ភេទប្រុស បានរត់ចេញពីរោងកម្មវិធី និងប្រឡាក់ឈាមពេញខ្លួនព្រមទាំងមានការប្រតាយប្រតប់គ្នាដោយខ្លួនពុំបានស្គាល់អ្នកទាំងនោះទេ ឃើញដូច្នេះខ្លួនក៏បានចូលទៅឃាត់ហើយពួកគេក៏បានបែកចេញពីគ្នា បន្ទាប់មកខ្លួនក៏បានឃើញឈ្មោះ បាវ ភេទប្រុស បានកាន់កាំបិតរត់មក ហើយក៏មានប្រជាពលរដ្ឋឃាត់ឈ្មោះ បាវ មិនចូលទៅ បន្ទាប់ឈ្មោះ [redacted] ចិន្តា ក៏បានត្រូវគេយកទៅមន្ទីពេទ្យទៅ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ខ្លួនមានឈ្មោះ [redacted] ចិន្តា ភេទប្រុស , ឈ្មោះ [redacted] បូរ៉ា ភេទប្រុស , ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស និងប្អូននាក់ទៀតដែលខ្លួនមិនចាំឈ្មោះ បានអង្គុយផឹកស៊ីក្នុងកម្មវិធីឡើងគេហដ្ឋានថ្មី របស់ឈ្មោះ [redacted] ភឿន ភេទស្រី នៅក្នុងភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ពេលកំពុងតែផឹកស៊ីពេលនោះឈ្មោះ [redacted] ចិន្តា បានទាស់ពាក្យសំដីគ្នាជាមួយបុរសម្នាក់ដែលអង្គុយតុជាមួយគ្នា អង្គុយជាប់ខ្លួនកុំអោយទាស់ពាក្យសំដីគ្នា ស្រាប់តែពេលនោះបក្ខពួករបស់បុរសដែលអង្គុយជាប់ខ្លួនប្រមាណ ជាជិតដប់នាក់ មានអ្នកខ្លះកាន់កែវក្នុងដៃ អ្នកខ្លះកាន់កៅអី អ្នកខ្លះកាន់កាំបិត មកព្រួតគ្នាវាយឈ្មោះ [redacted] ចិន្តា ឃើញដូច្នេះខ្លួនក៏ចូលទៅឃាត់ក៏ត្រូវគេវាយត្រូវមួយកៅអីជំរក្បាលពីលើ ខ្លួនបានដើរចេញឃើញបុរសម្នាក់ដែលជាអ្នកចាក់ម៉េក្រូ បានយកកាំបិតកាប់ទៅលើឈ្មោះ [redacted] ចិន្តា និងបក្ខពួក បានព្រួតគ្នាវាយមកមានគេឃាត់យកឈ្មោះ [redacted] ចិន្តា ចូលក្នុងផ្ទះម្ចាស់កម្មវិធី ទើបគេបែកគ្នាចេញទៅបាត់អស់ទៅ ដោយឃើញឈ្មោះ [redacted] ចិន្តា រងរបួសដៃ និងក្បាលហូរឈាមច្រើនពេក ក៏ត្រូវគេដឹកបញ្ជូនទៅកាន់មន្ទីរពេទ្យទៅ។ បន្តិចក្រោយមកសមត្ថកិច្ចប៉ុស្តិ៍ឈើខ្មៅ ផ្ទះខ្លួនវិញមក។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២២ ដោយមានបងប្អូនស្គាល់គ្នាបានហៅក្នុងកម្មវិធីឡើងផ្ទះនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល លុះដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង ៣០នាទី លុះបានទៅដល់ក៏បានជួបជុំបងប្អូននាក់ភូមិជាមួយគ្នា ដោយឈ្មោះ [redacted] ចិន្តា ភេទប្រុស នៅភូមិជាមួយគ្នា , ឈ្មោះ [redacted] បូរ៉ា ភេទប្រុស និងឈ្មោះ [redacted] ពិសិទ្ធ ភេទប្រុស និងខ្លួនផ្ទាល់ក្រៅពីនេះបងប្អូននាក់នៅត្រើយកោះ ពេលនោះភៀវទៅផ្ទះជិតអស់ហើយអ្នករាំក៏ជិតទៅផ្ទះអស់ដែរ លុះដល់ម៉ោង ២១ ក៏នាំបងប្អូនប្រមូលគួបគ្នាតុពីរ ជាមួយបងប្អូននាក់ត្រើយកោះក៏ជល់កែវគ្នាទៅវិញទៅមករួចក៏បានទាស់ពាក្យសំដីគ្នាជាមួយឈ្មោះ [redacted] ចិន្តា និងអ្នកផ្សេង ស្រាប់តែខ្លួនឃើញមនុស្សម្នាក់ទៀតរត់ទៅយកកាំបិតធ្វើត្រីរត់មកវិញ ចំណែកកាប់នៅលើជនរងគ្រោះ ក៏ខ្លួនពុំបានឃើញបន្ទាប់មកក៏ឃើញចំដៃឈាមក្បាលរត់ចេញមកក្រៅ ហើយពួកខ្លួនក៏យកជនរងគ្រោះទៅមន្ទីរពេទ្យទៅ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ម៉ៅ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៩ និង ០០នាទី ខ្លួនបានទៅចូលរួមកម្មវិធីឡើងគេហដ្ឋានថ្មី របស់ឈ្មោះ [redacted] ភឿន នៅក្នុងភូមិជាមួយគ្នា ពេលទៅដល់ខ្លួនបានចូលរួមកម្មវិធី ដោយបានអង្គុយតុជាមួយអ្នកនៅក្នុងភូមិជាមួយគ្នា ហើយក្រោយមកតុខ្លួនបានបែកគ្នាខ្លួនក៏ដើរចេញមកផ្ទះវិញ ដើរចេញបានបន្តិចអ្នកភូមិម្នាក់ដែលខ្លួនមិនចាំឈ្មោះ បានហៅខ្លួនអោយចូលតុជាមួខ្លួនក៏ចូលទៅអង្គុយ ដោយក្នុងតុនោះមានអ្នកក្រៅភូមិដែលខ្លួនមានស្គាល់ឈ្មោះ អង្គុយរួមតុដែរ ពីរបីនាក់ ខ្លួនបានអង្គុយក្បែរបុរសម្នាក់ដែលខ្លួនមិនស្គាល់ ពេលខ្លួនកំពុងតែផឹក ម្នាក់ដែលអង្គុយជាប់ខ្លួននោះបានសួរខ្លួនថា ឯងអាស្មោមែន ខ្លួនក៏ប្រាប់ថា អាស្មោ ហើយគ្រាន់តែនិយាយមិនទាន់ផុតមាត់ផងស្រាប់តែម្នាស់ដែលសួរខ្លួននោះបានចាប់ក្បាលខ្លួនអុកទៅលើតុ ខ្លួនស្ទុះរកវាយវិញក៏ត្រូវឈ្មោះ [redacted] គង់បានចាប់ខ្លួនជាប់ ពេលនោះម្នាក់ដែលចាប់ខ្លួន អុកក្បាលជាមួយតុបានរត់ចេញទៅខាងក្រៅរោង ខ្លួនឃើញ



Scanned with CamScanner

គេផ្អើលឈូឆរខាងក្រៅ រោងកម្មវិធី តែមិនបានដឹងថា អ្នកណាវាយអ្នកណាឡើយ ដោយខ្លួនទៅខាងក្នុងរោង រហូតដល់ស្ងាត់បែកគ្នាអស់ទើបឈ្មោះ [redacted] គង់ លែងខ្លួន ខ្លួនក៏ដើរត្រឡប់មកដេកនៅផ្ទះវិញទៅ។

-តាមចម្លើយសាក្សីឈ្មោះ [redacted]គង់ បានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ៣០នាទី ខ្លួនបានចូលរួមកម្មវិធីឡើងផ្ទះរបស់ឈ្មោះ [redacted] អឿន ស្ថិតនៅក្នុងភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ដោយខ្លួនបានអង្គុយតុជាមួយឈ្មោះ [redacted] ម៉ៅ ភេទប្រុស ឈ្មោះ [redacted]ចិន្តា ភេទប្រុស និងអ្នកមួយចំនួនទៀត ដែលពុំបានស្គាល់ឈ្មោះ បន្ទាប់មកឈ្មោះ [redacted] ចិន្តា ក៏បានសុំឈ្មោះ ខន ម៉ៅ ចាប់ដៃ ហើយឈ្មោះ [redacted]ម៉ៅ ក៏បានហុចដៃទៅចាប់ប៉ុន្តែឈ្មោះ [redacted]ចិន្តា ពុំបានចាប់ដៃទេ បែរជាចាប់ក្បាលឈ្មោះ [redacted]ម៉ៅ បោកនិងតុ បណ្តាលឱ្យពក បន្ទាប់មកឈ្មោះ [redacted] ចិន្តា ក៏បានរត់ចេញទៅខាងក្រៅ ហើយខ្លួនក៏បានឃាត់ឈ្មោះ [redacted] ម៉ៅ មិនអោយចេញទៅតាម ហើយខ្លួន និងឈ្មោះ [redacted] ម៉ៅ ក៏បានអង្គុយហូបស្រាបៀរបន្តទៀត មួយសន្ទុះក្រោយមកខ្លួន និងឈ្មោះ ម៉ៅ ក៏បានដើរចេញមកក្រៅក៏លឺគេនិយាយថា មានគេវាយគ្នា ខ្លួន និងឈ្មោះ [redacted]ម៉ៅ ក៏បានដើរត្រឡប់ទៅផ្ទះរៀងខ្លួន។

-តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៨៤១ ដកសស ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ[redacted] បាវ, ឈ្មោះ [redacted] និត និងឈ្មោះ [redacted]ឈី ពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន។

-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ហេតុនេះតុលាការ នឹងធ្វើការពិចារណាពីបញ្ហានេះ។

-មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងអំណានចម្លើយជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយសាក្សី, សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងតាមការពិនិត្យឯកសារភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងបញ្ជាក់ថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២៣ ជនជាប់ចោទឈ្មោះ[redacted] បាវ ភេទប្រុស អាយុ ៣០ឆ្នាំ, ឈ្មោះ [redacted] និត ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រាកដមែន។

-ជនជាប់ចោទឈ្មោះ[redacted] បាវ, ឈ្មោះ [redacted] និត និងឈ្មោះ [redacted]ឈី ជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដែលបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] បាវ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted]និត ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ និង ឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិត្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា បានដកពាក្យបណ្ដឹងឈប់ប្ដឹងក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ១០៥៩អក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ តាមពាក្យសុំដកពាក្យបណ្ដឹង ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០២២។

## ហេតុដូច្នេះ ទីនិច្ឆ័យសេចក្ដី

១-ផ្ដន្ទាទោសលើជនជាប់ចោទ ៖

១.១-ឈ្មោះ [redacted]បាវ ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ប៉ុន្តែ ទោសនេះត្រូវព្យួរជាធម្មតា។

១.២-ឈ្មោះ [redacted]និត ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ប៉ុន្តែ ទោសនេះត្រូវព្យួរជាធម្មតា។

១.៣-ឈ្មោះ [redacted] ឈី ភេទប្រុស អាយុ ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ ប៉ុន្តែ ទោសនេះត្រូវព្យួរជាធម្មតា។

ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិក្រើយកោះ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាម បញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បាវ, ឈ្មោះ [redacted] និត និងឈ្មោះ [redacted] ឈី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បាវ។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ហត្ថលេខា និងត្រា** **ចៅក្រមជំនុំជម្រះ ហត្ថលេខា និងត្រា**

[redacted] [redacted]

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner